# រូបសំណាកយុថ្កានៅទីរួមខេត្តកំពង់ធំ

## (កេរដំណែលបេតិកភណ្ឌសម័យអាណានិគមបារាំង)

ចាប់ពីឆ្នាំ១៩១០មក រ៉េស៊ីដង់បារាំងប្រចាំនៅរដ្ឋបាលកំពង់ធំ បានចាប់ផ្ដើមកសាងហេដ្ឋារចនាសម្ព័ន្ធនៅទីរួមខេត្តកំពង់ធំជាបន្តបន្ទាប់។ ដំបូងឡើយ នៅរវាងឆ្នាំ១៩១០ដល់១៩១៧ គេបានកសាងកន្លែងស្នាក់នៅសម្រាប់មន្ត្រីរ៉េស៊ីដង់បារាំងជាមុនសិន ដែលគេហៅសំណង់នោះថា **“Hôtel de la Résidence”** (អាចហៅជាភាសាខ្មែរថា "សណ្ឋាគាររ៉េស៊ីដង់")។ ប៉ុន្មានឆ្នាំក្រោយមក គេចាប់ផ្ដើមកសាងរូបសំណាកយុថ្កាមួយ **(L’Ancre)** ដាក់តាំងនៅតាមបណ្ដោយមាត់ស្ទឹងសែន នៅរវាងឆ្នាំ១៩២០ និងចុងក្រោយដើម្បីសម្រួលចរន្តសេដ្ឋកិច្ចឱ្យកាន់តែងាយស្រួល គេបានសាងសង់ស្ពានបេតុងមួយចាប់ពីឆ្នាំ១៩២៣ ដល់១៩២៥។ រូបសំណាកយុថ្កាដែលសាងសង់ឡើងនៅកណ្ដាលក្រុងស្ទឹងសែន ឬស្ទើរតែចំពាក់កណ្ដាលចំណុចកណ្ដាលនៃប្រទេសកម្ពុជានេះ មិនមែនជាភាពចៃដន្យនោះឡើយ ពោល គឺវាបានបង្កប់នូវអត្ថន័យផ្នែកប្រវត្តិសាស្ត្រយ៉ាងជ្រាលជ្រៅដែលគួរតែសិក្សាស្វែងយល់។ តើរូបសំណាកយុថ្កានេះបានឆ្លុះបញ្ចាំងអំពីតថភាពប្រវត្តិសាស្ត្រ និងសិល្បៈយ៉ាងណាខ្លះ?

ជាទូទៅ ការកសាងរូបសំណាកយុថ្កា ស្ទើរតែក្លាយជាវប្បធម៌របស់ពួកលោកខាងលិចទៅហើយ។ ឧទាហរណ៍ នៅប្រទេសបារាំង (កំពង់ផែនៅទីក្រុង Marseille ឬ Bordeaux) និងចក្រភពអង់គ្លេស (កំពង់ផែនៅទីក្រុង Greenwich, Portsmouth ឬ Liverpool) មានការកសាងរូបសំណាកនេះស្ទើរគ្រប់កំពង់ផែ និងក្រុងសំខាន់ៗ។ សំណង់រូបសំណាកយុថ្កាទាំងនោះ គឺសុទ្ធសឹងមានអត្ថន័យយ៉ាងជ្រាលជ្រៅក្នុងផ្នត់គំនិតរបស់ប្រជាជននៅលោកខាងលិច ព្រោះរូបសំណាកយុថ្កានេះជានិមិត្តរូបតំណាងឱ្យក្ដីសង្ឃឹម ភាពរឹងមាំ សន្តិសុខ ការការពារ ចំណងមិត្តភាព ភាពជាម្ចាស់ការ និងការតាំងទី ហើយជាពិសេសជាការរំឭកដឹងគុណទៅដល់វីរភាពរបស់កងទ័ពជើងទឹកឬនាវិកដែលបានពលីជីវិតក្នុងសមុទ្រដើម្បីឱ្យសេចក្ដីជាតិរីកចម្រើន។

ត្រឡប់មករូបសំណាកយុថ្កានៅទីរួមខេត្តកំពង់ធំវិញ ជាសំណង់កសាងឡើងអំពីបេតុងបែរមុខទៅទិសខាងកើត តាមបណ្ដោយមាត់ស្ទឹងសែន ត្រង់ចំណុចភូមិពោធិបាក់ក សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដែលមានចម្ងាយប្រមាណ ៨០០ ម៉ែត្រ ប៉ែកអាគ្នេយ៍ស្ពាន

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

កំពង់ធំ(ស្ពានបារាំង)។ យោងទៅតាមរបាយការណ៍របស់ក្រសួងសាធារណការក្នុងរដ្ឋបាលបារាំង ចាប់ពីឆ្នាំ១៩២០ដល់១៩៣៥ បង្ហាញឱ្យឃើញថាសំណង់នេះកសាងឡើងចប់ជាស្ថាពរនៅរវាង ឆ្នាំ១៩២០ ក្នុងពេលដែលលោក ហ្សង់ ឌុយបូស (Jean Dubosc) ជារ៉េស៊ីដង់កំពង់ធំ (១៩១៨ - ១៩២០)។ លោក គឺអ្នកបង្កើយគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនៅទីរួមខេត្តកំពង់ធំ បន្តពី លោក ល្វីស៍ រ៉េណូត៍ (Louis Reynaut) ដែលជាអតីតរ៉េស៊ីដង់កំពង់ធំ ចន្លោះឆ្នាំ១៩១៤-១៩២០ ក្នុងគោលបំណងកែប្រែឱ្យក្រុងកំពង់ធំ ក្លាយទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្មកសិផលធំជាងគេ នៅតំបន់ជុំវិញបឹងទន្លេសាប។ គួរកត់សម្គាល់ថា បារាំងតែងតែរៀបចំក្រុងដោយអនុវត្តតាមទ្រឹស្តី "សមាសភាពទីក្រុង" (Composition Urbaine) និងតាមបែបទស្សនវិស័យច្បាស់លាស់ (Perspective Pointue) ដើម្បីឱ្យក្រុងមើលទៅមានសណ្តាប់ធ្នាប់ត្រឹមត្រូវ និងមានអត្តសញ្ញាណច្បាស់លាស់។ ដូច្នេះហើយ រូបសំណាកយុថ្កានៅក្រុងកំពង់ធំ បារាំងបានជ្រើសរើសទីតាំងដែលមានអ័ក្សស្របគ្នា ជាមួយសំណង់ណាមួយ ពោល គេបានជ្រើសរើសយកសំណង់សណ្ឋាគាររេស៊ីដង់ជាអ័ក្សគោល ភ្ជាប់គ្នាជាមួយទីតាំងដែលកសាងរូបសំណាកយុថ្កា។ ករណីនេះមានន័យថា នៅចុងទសវត្សរ៍ ១៩១០ ចំណុចកសាងរូងសំណាកយុថ្កា គឺស្ថិតនៅត្រង់ផ្លូវប្រមុះជ្រូក ប្រសព្វគ្នារវាងផ្លូវប្រជាធិប តេយ្យនិងផ្លូវមួយខ្សែទៀតដែលចេញពីសណ្ឋាគាររ៉េស៊ីដង់ ស្ថិតនៅតាមបណ្តោយស្ទឹងសែន ហើយក្រោយមកទៀតនៅពេលគេកសាងស្ពានបេតុងរួចរាល់ ទីតាំងរូបសំណាកយុថ្កានេះ គឺភ្ជាប់ គ្នាជាមួយពីស្ពានបារាំងដូចគ្នា។ បើសិនជាសំណង់ទាំងបីមកគិត ប្លង់នគរូបនីយកម្មដែលរៀបចំ ដោយវិស្វករបារាំង អាចហៅថា "ត្រីកោណយុទ្ធសាស្ត្រ" នៃក្រុងកំពង់ធំ ពោល គឺស្ពានបារាំង តំណាងឱ្យការភ្ជាប់ផ្លូវគោកនិងទំនើបកម្ម រូបសំណាកយុថ្កាតំណាងឱ្យអត្តសញ្ញាណផ្លូវទឹកនិង ពាណិជ្ជកម្ម រីឯសណ្ឋាគាររ៉េស៊ីដង់ (សាលាខេត្តចាស់) តំណាងឱ្យអំណាចគ្រប់គ្រងនិងច្បាប់។ សម័យក្រោយមក ផ្លូវនៅតាមបណ្តោយមាត់ស្ទឹងសែននេះ លែងមានដំណើរការទៀតហើយ ដោយសារតែការបាក់ច្រាំងស្ទឹងប៉ះចំផ្លូវប្រមាណ១០ម៉ែត្រ (ខាងកើតរូបសំណាកយុថ្កា) នៅរវាង ឆ្នាំ១៩៨៥។ ចាប់ពីពេលនោះហើយ ដែលនាំឱ្យមានផ្ទះប្រជាពលរដ្ឋមួយចំនួន សាងសង់ឡើង នៅតាមបណ្តោយច្រាំងស្ទឹងសែន។

ទីតាំងរូបសំណាកយុថ្កានេះទៀតសោត ស្ថិតនៅត្រង់ផែថ្មនៃក្រុងកំពង់ធំ ដែលជំនាន់នោះ បារាំងបានចាក់បេតុងធ្វើជាផែថ្ម ដើម្បីសម្រួលដល់ការផ្ទេរទំនិញពីទូកធំៗ (សម័យក្រោយមកគេ ធ្វើរបាំងឈើជំនួសវិញ)។ ហេតុដូច្នេះហើយ រូបសំណាកយុថ្កាដែលបានកសាងឡើង គឺអាចជា

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

សញ្ញាឬនិម្មិតរូបប្រាប់ដល់អ្នកបើកនាវាថា ទីនោះគឺជាចំណុចដែលមានជម្រៅទឹកជ្រៅ ដែលផ្តល់សុវត្ថិភាពសម្រាប់ការចតទូក ឬនាវាធំតូចបាន ហើយជាមជ្ឈមណ្ឌលកំពង់ផែអាចដោះដូរទំនិញជាផ្លូវការ ដែលមានការគ្រប់គ្រងយ៉ាងហ្មត់ចត់ពីសំណាក់អាជ្ញាធររដ្ឋបាលបារាំងប្រចាំកំពង់ធំ។ មិនត្រឹមតែប៉ុណ្ណោះ រូបសំណាកយុថ្កានេះ តំណាងឱ្យនិម្មិតរូបសំខាន់ៗចំនួន ២ ទៀត។ និម្មិតរូបទី១ យុថ្កាតំណាងឱ្យការតាំងទី និងសន្តិភាពពោល គឺបង្ហាញថាអាណាព្យាបាលបារាំងបានមកដល់កំពង់ធំ ហើយបានបោះយុថ្កា (ប្រៀបដូចជាការតាំងមូលដ្ឋាន) ដើម្បីការពារ និងរក្សាសន្តិសុខឱ្យប្រជាជន រីឯសន្តិភាពនោះ គឺសំដៅដល់និម្មិតរូបនៃការបញ្ចប់ភាពមិនច្បាស់លាស់និងសង្គ្រាមនានា រួមបញ្ចូលទាំងការបញ្ចប់សង្គ្រាមលោកលើកទី១ (ឆ្នាំ១៩១៨) ផង ជំនួសមកវិញនូវភាពរឹងមាំដូចយុថ្កា ក្រោមការដឹកនាំរបស់ជនជាតិបារាំង។ និម្មិតរូបទី២ រូបសំណាកយុថ្កា សាងសង់ឡើងដើម្បីរំឭកនឹកគុណដល់ "សេវាកម្មនាវាចរណ៍" ព្រោះបារាំងមានអង្គភាពមួយហៅថា "សេវាកម្មរុករក និងធារាសាស្ត្រ" (Service de la Navigation et de l'Hydraulique) ដោយគេចាត់ទុកសំណង់យុថ្កាជា "វិមានតូច" (Petit monument) តំណាងឱ្យភាពជោគជ័យនៃវិស្វកម្មបារាំង ក្នុងការដោះស្រាយបញ្ហាទឹកជំនន់ និងការធ្វើឱ្យស្ទឹងសែនអាចធ្វើនាវាចរណ៍បានពេញមួយឆ្នាំ ទោះក្នុងរដូវប្រាំងក៏ដោយ។

ដោយឡែក ចំពោះលក្ខណៈទូទៅ និងរូបរាងរបស់យុថ្កាដែលគេសាងសង់ឡើងនៅមាត់ស្ទឹងសែន ទីរួមខេត្តកំពង់ធំ នាសម័យបារាំងនោះ គឺជាប្រភេទយុថ្កាមានធ្នឹម (Stock Anchor) ឬហៅម្យ៉ាងទៀតថាយុថ្កាបែបបុរាណ ដែលគេប្រើប្រាស់យ៉ាងទូលំទូលាយលើនាវាចម្បាំង និងនាវាពាណិជ្ជកម្មធំៗក្នុងស.វ.ទី១៩ និងដើមស.វ.ទី២០។ យុថ្កានេះមានបង្គោលកណ្ដាល និងមានដៃពីរ រួមជាមួយផ្ចាំងកណ្ដាលសម្រាប់ចាក់ទម្លុះទៅក្រោម។ នៅផ្នែកខាងលើមានធ្នឹមទទឹង ដែលជួយឱ្យយុថ្កាអាចផ្ងារខ្លួន និងចាក់ចូលទៅក្រោមបានជាប់ល្អ។ កាលដើមឡើយ នៅផ្នែកខាងលើចំបង្គោលកណ្ដាលគេបានលម្អដោយរូបសត្វព្រាបមួយក្បាល ពោល គឺជានិម្មិតរូបតំណាងឱ្យសន្តិភាពយ៉ាងពេញលេញ បន្ទាប់អំពីការបញ្ចប់សង្គ្រាមលោកលើកទី១ នាឆ្នាំ១៩១៨។ ប៉ុន្តែ រូបសត្វព្រាបនេះបានបាត់នៅរវាងជាង២០ឆ្នាំមុន។ នៅរវាងជាង២០ឆ្នាំមុន អ្នកស្រុកបានលាបពណ៌មាសនៅលើយុថ្កានេះ និងមានរុំក្រណាត់ពណ៌ក្រហម (តាមជំនឿជីវចល)។ លើសពីនេះដោយសារតែមានដីដំបូកដុះចំរូបសំណាកយុថ្កានេះ អ្នកស្រុកក៏គោរពជាប់វត្ថុនេះជាប់ជាប្រចាំពោល គឺបង្ហាញអំពីការផ្លាស់ប្តូរពី "**រូបសំណាក**" ដែលមានភ្ជាប់ជាមួយនិម្មិតរូបជាច្រើនយ៉ាងនៃ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

រដ្ឋបាលបារាំង មកជា “**វត្ថុសក្ការបូជា**” របស់ជនជាតិខ្មែរនាសម័យបច្ចុប្បន្ន។ ក្រៅអំពីនេះ រូបសំណាកយុថ្កានេះ ដាក់នៅលើជើងទម្របេតុងដែលមានរូបរាងដូចនាវា។

ជារួមមក រូបសំណាកយុថ្កានៅទីរួមខេត្តកំពង់ធំ ដែលជាកេរដំណែលបេតិកភណ្ឌនៅសម័យអាណានិគមបារាំង មិនមែនគ្រាន់តែជាសំណង់លម្អមាត់ទឹកប៉ុណ្ណោះទេ ប៉ុន្តែគឺជាទិដ្ឋភាពប្រវត្តិសាស្ត្រដែលបញ្ជាក់អំពីតួនាទីក្រុងកំពង់ធំ ជាមជ្ឈមណ្ឌលរដ្ឋបាល និងពាណិជ្ជកម្មតាមផ្លូវទឹកដ៏សំខាន់នាសម័យអាណានិគម។ តាមរយៈការរៀបចំក្នុងទម្រង់ «ត្រីកោណយុទ្ធសាស្ត្រ» រួមជាមួយសណ្ឋាគាររ៉េស៊ីដង់ និងស្ពានបារាំង រូបសំណាកយុថ្កានេះបានដើរតួនាទីយ៉ាងសំខាន់ទាំងផ្នែកបច្ចេកទេសនាវាចរណ៍ និងជានិមិត្តរូបនៃសន្តិភាពក្រោយសង្គ្រាមលោកលើកទី១។ ទោះបីជាបច្ចុប្បន្ន តួនាទីដើមនៃយុថ្កានេះត្រូវបានផ្លាស់ប្តូរមកជាវត្ថុសក្ការបូជាតាមជំនឿជីវចលរបស់អ្នកស្រុកក៏ដោយ វានៅតែជាបេតិកភណ្ឌដ៏មានតម្លៃដែលឆ្លុះបញ្ចាំងអំពីការវិវឌ្ឍន៍នៃអារ្យធម៌នគរូបនីយកម្ម និងការរួមបញ្ចូលគ្នារវាងវប្បធម៌សិល្បៈខ្មែរ-បារាំង។ ការរក្សាបាននូវរូបសំណាកនេះ គឺជាការអភិរក្សនូវអត្តសញ្ញាណ និងបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រនៃទឹកដីខេត្តកំពង់ធំឱ្យនៅគង់វង្សសម្រាប់មនុស្សជំនាន់ក្រោយ។

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

## បញ្ជីឯកសារពិគ្រោះ


Brachet, A. (s.d.). *L'architecture coloniale au Cambodge: Le cas des chefs-lieux de province.* [En ligne] Paris: École française d'Extrême-Orient.

Direction des Travaux Publics de l'Indochine (1924). *Rapport annuel sur les travaux d'édilité et d'aménagement des centres urbains au Cambodge*. Phnom Penh: Imprimerie du Protectorat.

Gouvernement Général de l'Indochine (1925). 'Travaux Publics: Pont sur le Stung Sen à Kompong Thom', *Bulletin Économique de l'Indochine*, 28(2), pp. 115-120.

Institut Français du Cambodge (2015). L'héritage colonial français au Cambodge : Urbanisme et Architecture. Phnom Penh: IFC.

Ministère de la Culture et des Beaux-Arts du Cambodge (2020). *Inventory of Colonial Heritage in Kampong Thom Province*. Phnom Penh: Department of Heritage.

Résidence Supérieure du Cambodge (RSC) (1918-1920). *Rapports mensuels de la Résidence de Kompong Thom (Période de Jean Dubosc)*. Archives Nationales du Cambodge, Dossier No. 425.


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION




រូបលេខ១៖ រូបសំណាកយុថ្កា នៅទីរួមខេត្តកំពង់ធំ




រូបលេខ២៖ រូបសំណាកយុថ្កា នៅទីរួមខេត្តកំពង់ធំ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី




រូបលេខ៣៖ រូបសំណាកយុថ្កា នៅទីរួមខេត្តកំពង់ធំ




រូបលេខ៤៖ រូបសំណាកយុថ្កា នៅទីរួមខេត្តកំពង់ធំ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី